**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

**ជំពូកទី ២**

**អំពីលិខិតឆ្លងដែនការទូត**

**មាត្រា ២.-**

លិខិតឆ្លងដែនការទូតចេញថ្វាយ និងជូនដល់ឥស្សរជនជាន់ខ្ពស់ និងមន្ត្រីការទូតខ្មែរទៅតាមលំដាប់នៃឋានន្តរសក្តិ និងមុខតំណែង ព្រមទាំងសហព័ទ្ធ និងកូនដែលទៅក្នុងបន្ទុកនៅលីវហើយមានអាយុក្រោម ១៨ ឆ្នាំ ដូចខាងក្រោម ៖

១- ព្រះមហាវីរក្សត្រ ព្រះវររាជមាតា ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬសម្តេចព្រះរាជអគ្គមហេសី ។

២- ព្រះរាជបុត្រា ព្រះរាជបុត្រី ព្រមទាំងព្រះរាជវង្សានុវង្ស ដែលបញ្ជាក់ដោយក្រសួងព្រះបរមរាជវាំង ។

៣- ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភា ប្រធាន អនុប្រធាន និងសមាជិករដ្ឋសភា ។

៤- ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

៥- នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ព្រមទាំងរដ្ឋលេខាធិការ ( ដែលជាប្រធានស្ថាប័នរបស់រាជរដ្ឋាភិបាល ) ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងអគ្គលេខាធិការរាជរដ្ឋាភិបាល ។

៦- ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

៧- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងអគ្គស្នងការនគរបាលជាតិ ។

៨- ឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ និង ឥស្សរជនដែលមានងារជាសម្តេច ។

៩- អតីតប្រធានព្រឹទ្ធសភា អតីតប្រធានរដ្ឋសភា អតីតនាយករដ្ឋមន្ត្រី អតីតឧបនាយករដ្ឋមន្ត្រី និងអតីតរដ្ឋមន្ត្រីក្រសួងការបរទេស ។

១០-នាយកខុទ្ទកាល័យព្រះមហាក្សត្រ នាយកខុទ្ទកាល័យប្រធានព្រឹទ្ធសភា នាយកខុទ្ទកាល័យប្រធានរដ្ឋសភា នាយកខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

១១- ប្រធានពិធីការរបស់ព្រះមហាក្សត្រ ប្រធានពិធីការរបស់ប្រធានព្រឹទ្ធសភា ប្រធានពិធីការរបស់ប្រធានរដ្ឋសភា និងប្រធានពិធីការរបស់នាយករដ្ឋមន្ត្រី ។

១២-មន្ត្រីការទូតចាប់ពីអនុព័ន្ធឡើងទៅ ដែលត្រូវទៅធ្វើការនៅស្ថានទូត និងកុងស៊ុលនៅបរទេស ។

**មាត្រា ៣.-**

លិខិតឆ្លងដែនការទូតចេញថ្វាយ និងជូនដល់មន្ត្រីរាជការ និងឥស្សរជនខ្មែរទៅតាមលំដាប់នៃឋានន្តរសក្តិ និងមុខតំណែងសម្រាប់បំពេញបេសកកម្មដូចខាងក្រោម ៖

១- ប្រធាន និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

៣- រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងស្ថាប័ននានា ។

៤- ប្រធានអាជ្ញាធរជាតិ ប្រធានគណៈកម្មាធិការជាតិ និងប្រធានស្ថាប័នថ្នាក់ជាតិនានា ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

៥- ប្រធាន និងអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ប្រធាន និងអនុប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

៦- អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការក្រសួងនានា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ។

៧- ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ។

៨- នាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ដែលតែងតាំងដោយព្រះរាជក្រឹត្យ ។

៩- ទីប្រឹក្សាថ្នាក់ដឹកនាំ / ឥស្សរជន និងមន្ត្រីកាន់តំណែងនានា ដែលមានឋានៈស្មើរដ្ឋលេខាធិការឡើងទៅ ។

១០-មន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈដែលមានតំណែងជាអគ្គនាយក ឬអគ្គាធិការដែលតែងតាំងដោយព្រះរាជក្រឹត្យ និងប្រធាននាយកដ្ឋាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (ស្របតាមការអនុវត្តន៍អន្តរជាតិ) ។

១១-មន្ត្រីផ្នែកយោធានិងនគរបាលដែលមានតំណែងជា អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិ អគ្គមេបញ្ជាការរង នាយសេនាធិការចម្រុះ នាយរងសេនាធិការចម្រុះ មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអគ្គស្នងការរងនគរបាលជាតិ ។

១២- អភិបាលរាជធានី និងខេត្ត ។

សហព័ទ្ធព្រមទាំងកូននៅក្នុងបន្ទុករបស់ឥស្សរជននិងមន្ត្រីរាជការខាងលើពុំត្រូវផ្តល់លិខិតឆ្លងដែនការទូតឡើយ ។

**មាត្រា ៤.-**

លិខិតឆ្លងដែនការទូតចេញថ្វាយ និងប្រគេនសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ ទាំងពីរគណៈ និងមន្ត្រីសង្ឃដែលមានងារជាសម្តេច ។

**មាត្រា ៥.-**

សុពលភាពនៃលិខិតឆ្លងដែនការទូតមានរយៈពេលដំបូង ០៣ ( បី ) ឆ្នាំ ហើយអាចបន្តសម្រាប់រយៈពេល ០៣ ( បី ) ឆ្នាំម្តង ក្នុងករណីដែលអ្នកកាន់លិខិតឆ្លងដែននេះនៅមានឋានៈ ឬមុខតំណែងដូចមានចែងក្នុងមាត្រា ២ មាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យនេះ ។ មន្ត្រីការទូតដែលចប់អាណត្តិបេសកកម្ម មន្ត្រីអស់ឋានៈ ឬមុខតំណែង មន្ត្រីចូលនិវត្តន៍ មន្ត្រីដែលមានពិរុទ្ធដែលត្រូវបានព្យួរក្របខ័ណ្ឌ និងមន្ត្រីដែលឈប់សម្រាកយូរ ដោយគ្មានបៀវត្សចាប់ពី ០៦ ( ប្រាំមួយ ) ខែឡើងទៅ នឹងពុំមានសិទ្ធិប្រើប្រាស់លិខិតឆ្លងដែនការទូតទៀតទេ ។

## ជំពូកទី ៣

## អំពីលិខិតឆ្លងដែនផ្លូវការ

**មាត្រា ៦.-**

១- លិខិតឆ្លងដែនផ្លូវការផ្តល់ជូនមន្ត្រីរាជការខ្មែរ សម្រាប់តែទៅបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេស ប៉ុណ្ណោះ ៖

ក- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ខ- ទីប្រឹក្សា ឬជំនួយការមានឋានៈស្មើប្រធាននាយកដ្ឋាន ដល់ អនុរដ្ឋលេខាធិការ ។

គ- អនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ ចៅក្រម ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង ។

ឃ- អនុប្រធានអាជ្ញាធរជាតិ អនុប្រធានគណៈកម្មាធិការជាតិ អនុប្រធានក្រុមប្រឹក្សាជាតិ និងអនុប្រធានស្ថាប័នថ្នាក់ជាតិនានា ។

ង- ប្រធានសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ ។

ច- មន្ត្រីដែលមានមុខតំណែងចាប់ពីអនុប្រធានការិយាល័យឡើងទៅ ។

ឆ- មន្ត្រីយោធា និងនគរបាលចាប់ពីវរសេនីយ៍ត្រីឡើងទៅ ។

ជ- បុគ្គលិកបម្រើសេវាស្ថានបេសកកម្មការទូត និងកុងស៊ុលនៅក្រៅប្រទេស ។

ឈ- អង្គរក្សអមដំណើរគណៈប្រតិភូថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ។

២- លិខិតឆ្លងដែនផ្លូវការប្រគេនព្រះសង្ឃទាំងពីរគណៈចាប់ពីអនុគណឡើងទៅ ។

**មាត្រា ៧.-**

មន្ត្រីរាជការ ដែលមានមុខតំណែងក្រោមអនុប្រធានការិយាល័យ មន្ត្រីយោធា និងមន្ត្រីនគរបាលដែលមានឋានន្តរសក្តិក្រោមវរសេនីយ៍ត្រីត្រូវកាន់លិខិតឆ្លងដែនផ្លូវការនៅពេលបំពេញបេសកកម្មនៅបរទេស ។ ដោយឡែកបើទៅចូលរួមវគ្គសិក្សា ឬសិក្ខាសាលា មន្ត្រីទាំងនោះត្រូវកាន់លិខិតឆ្លងដែនធម្មតាដោយមិនបង់តម្លៃលិខិតឆ្លងដែន ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនឹងធ្វើកំណត់ទូតទៅស្ថានទូតពាក់ព័ន្ធដើម្បីសុំទិដ្ឋាការដោយពុំចាំបាច់បង់តម្លៃទិដ្ឋាការ ។

**មាត្រា ៨.-**

សុពលភាពនៃលិខិតឆ្លងដែនផ្លូវការមានរយៈពេលដំបូង ០៣ ( បី ) ឆ្នាំ ហើយអាចបន្តរយៈពេល ០៣ ( បី ) ឆ្នាំម្តង ។

## ជំពូកទី ៤
## សមត្ថកិច្ចផ្តល់ និងដកហូតលិខិតឆ្លងដែន

**មាត្រា ៩.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចផ្តល់លិខិតឆ្លងដែនការទូត និងផ្លូវការ ស្របតាមអនុក្រឹត្យនេះ ។

ការស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការត្រូវមានលិខិតស្នើសុំមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយបញ្ជាក់នូវកម្មវត្ថុនៃបេសកកម្ម រយៈពេល ថ្ងៃ ខែ និងប្រទេសដែលត្រូវទៅបំពេញបេសកកម្ម ។

លិខិតឆ្លងដែនការទូត និងផ្លូវការទាំងឡាយណាដែលពុំស្របទៅនឹងមាត្រា ២ មាត្រា៣ មាត្រា៤ និងមាត្រា៦ នៃអនុក្រឹត្យនេះនឹងលែងមានសុពលភាពប្រើប្រាស់ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដកហូត ឬបដិសេធរាល់លិខិតឆ្លងដែនការទូត និងផ្លូវការ ទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ។

រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានឆន្ទានុសិទ្ធិក្នុងការផ្តល់លិខិតឆ្លងដែនការទូត និងផ្លូវការដល់ឥស្សរជនណាម្នាក់ ក្នុងករណីចាំបាច់ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូតនិងផ្លូវការ និងអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ និងបទប្បញ្ញត្តិ

ទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យ នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ហោ ណាំហុង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ